# និន្នាការសេដ្ឋកិច្ចសង្គម

# Socio-Economic Trends

**ខែមិថុនា-កក្កដា ឆ្នាំ២០១៧**

**June - July 2017**

## មាតិកា


| | ទំព័រ |
|---|---|
| **ខ្លឹមសារសង្ខេប / Executive summary** | **២** |
| **១. និន្នាការសេដ្ឋកិច្ចកម្ពុជា / Cambodia economic trends** | **៥** |
| ១.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ / Consumer price index | ៥ |
| ១.២. វិស័យហិរញ្ញវត្ថុ / Finance | ៦ |
| ១.៣. វិស័យពាណិជ្ជកម្ម / Trade | ៨ |
| ១.៤. ការអនុវត្តថវិកា / Budget execution | ៩ |
| ១.៥. វិស័យវិនិយោគឯកជន / Private investment | ១០ |
| ១.៦. វិស័យទេសចរណ៍ / Tourism | ១០ |
| ១.៧. វិស័យសំណង់ / Construction | ១១ |
| **២. និន្នាការថ្លៃទំនិញសំខាន់ៗលើទីផ្សារអន្តរជាតិ / International commodity prices** | **១១** |
| ២.១. ថ្លៃប្រេងឆៅ (Crude oil price: Brent, WTI, Dubai) | ១១ |
| ២.២. ថ្លៃអង្ករ (Rice price: 5%, 25%, 100% broken) | ១១ |
| ២.៣. ថ្លៃកៅស៊ូ (Rubber price: TSR20, SGP/MYS) | ១២ |
| **៣. ឧបសម្ព័ន្ធ** | **១៣** |

## ខ្លឹមសារសង្ខេប

១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅភ្នំពេញក្នុងខែមិថុនា ឆ្នាំ២០១៧ បានកើនឡើង ០,១% ធៀបនឹងខែមុន និងបានកើនឡើង ២,៣% បើធៀបនឹង១ឆ្នាំមុន។ ក្នុងរយៈពេល៣ខែដើមឆ្នាំ២០១៧ ស្ថានភាពអតិផរណាប្រចាំឆ្នាំមានការកើនឡើងគួរឱ្យកត់សម្គាល់ ជាពិសេសលើថ្លៃក្រុមទំនិញម្ហូបអាហារ ប៉ុន្តែចាប់ពីខែមេសាមកអត្រាអតិផរណាបានថយចុះមកវិញដោយសារការថយចុះកំណើនថ្លៃភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ សម្លៀកបំពាក់ ការដឹកជញ្ជូន និងគមនាគមន៍ជាដើម។ តាមការធ្វើចំណោលគិតដល់ត្រឹមខែធ្នូ ឆ្នាំ២០១៧ អតិផរណាប្រចាំឆ្នាំ (year on year) អាចមានអត្រា ១,៩% ឬអតិផរណាមធ្យមប្រចាំឆ្នាំ (year average) អាចមានអត្រា ២,៩%។

២. *ឥណទាននិងអត្រាការប្រាក់÷* គិតត្រឹមខែមិថុនា ឆ្នាំ២០១៧ ឥណទានផ្តល់ដោយធនាគារពាណិជ្ជមានចំនួន ៦២.៧៦៩ប៊ីលានរៀល បានកើនឡើង ៣,៤% ធៀបនឹងខែមុន (កើនឡើង១៥,៥% បើធៀបនឹង១ឆ្នាំមុន), ក្នុងនោះឥណទានផ្តល់ដល់វិស័យសេវាកម្មមានចំនួន ៣៣.៧៤៧លានរៀល បានកើនឡើង ៣,៥%, ឥណទានដល់រូបវន្តបុគ្គលនិងផ្សេងៗមានចំនួន ១១.២៩៧លានរៀល បានកើនឡើង ៣,១% ក្នុងនោះភាគច្រើនជាឥណទានសម្រាប់ទិញផ្ទះកម្មសិទ្ធផ្ទាល់ខ្លួន។ អត្រាការប្រាក់ឥណទានធនាគារពាណិជ្ជនៅកម្ពុជាមាននិន្នាការថយចុះគួរកត់សម្គាល់ក្នុងឆ្នាំ២០១៧នេះ ប៉ុន្តែនៅមានអត្រាខ្ពស់ជាងប្រទេសជិតខាងក្នុងតំបន់ និងកំណើនឥណទានក៏នៅមានល្បឿនលឿនជាងប្រទេសជិតខាងផងដែរ។

*ការផ្គត់ផ្គង់រូបិយវត្ថុ÷* រូបិយវត្ថុទូទៅM2 បានបន្តកើនឡើងក្នុងដើមឆ្នាំ២០១៧នេះ, គិតត្រឹមខែមិថុនា ឆ្នាំ២០១៧ រូបិយវត្ថុទូទៅM2 មានចំនួន ៦៥.២៧១ប៊ីលានរៀល បានកើនឡើង ៣,៧% ធៀបនឹងខែមុន និងបានកើនឡើង ១៩,៨%។ អត្រាផលធៀបរូបិយវត្ថុទូទៅM2 នឹងផ.ស.សរបស់កម្ពុជាបានកើនឡើងគួរឱ្យកត់សម្គាល់ក្នុងរយៈពេល ៨ឆ្នាំចុងក្រោយនេះ ពោលគឺមានអត្រា ០,៣៨ ក្នុងឆ្នាំ២០១៩ និងមានអត្រា ០,៧១ ក្នុងឆ្នាំ២០១៦ ប៉ុន្តែអត្រានេះនៅមានកម្រិតទាបជាងក្នុងសេដ្ឋកិច្ចជិតខាងក្នុងតំបន់។

*អត្រាប្តូរប្រាក់÷* ប្រាក់រៀលបានថយចុះតម្លៃជាបន្តបន្ទាប់ចាប់ពីខែមីនាមក, គិត្រឹមខែកក្កដា ឆ្នាំ២០១៧នេះ អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារស្មើនឹង ៤.០៩៨រៀល/ដុល្លារ និងអត្រាខែមីនាកន្លងទៅស្មើនឹង ៤.០០៥រៀល/ដុល្លារ។ ទោះជាប្រាក់រៀលមាននិន្នាការថយចុះថ្លៃក៏ដោយ ការទិញចូលប្រាក់ដុល្លារដោយធនាគារជាតិនៅតែបន្តកើនឡើង, សម្រាប់ខែកក្កដា ឆ្នាំ២០១៧នេះ ធនាគារជាតិបានទិញចូលប្រាក់ដុល្លារអាមេរិក ១៨៦,៥លានដុល្លារ និងក្នុងរយៈពេល៧ខែដើមឆ្នាំនេះបានទិញចូលសរុប ៧១៥លានដុល្លារ។ ធនាគារជាតិកម្ពុជាបានធ្វើអន្តរាគមលើទីផ្សារប្តូរប្រាក់ដើម្បីគ្រប់គ្រងនិងរក្សាស្ថិរភាពអត្រាប្តូរប្រាក់ និងបានទិញចូលរូបិយប័ណ្ណដុល្លារអាមេរិកជាច្រើនក្នុងរយៈពេល៣ឆ្នាំចុងក្រោយនេះ ប្រមាណជិត ៨០០លានដុល្លារក្នុង១ឆ្នាំៗ។

៣. *ការនាំចូល÷* ក្នុងខែមិថុនា ឆ្នាំ២០១៧ ការនាំចូលគិតជាទឹកប្រាក់សរុបមានចំនួន ១.១៦៦លានដុល្លារ បានថយចុះ ១,២% ធៀបនឹងខែមុន, ក្នុងនោះការនាំចូលមុខទំនិញវាយនភ័ណ្ឌបានថយចុះ ៩,២% និងការនាំចូលប្រេងឥន្ធនៈបានថយចុះ ៤,៤%, តាមការសង្កេតការនាំចូលប្រេងឥន្ធនៈបានថយចុះគួរកត់សម្គាល់គិតចាប់ពីខែកុម្ភៈដើមឆ្នាំនេះមក។ *ការនាំចេញ÷* ក្នុងខែមិថុនា ឆ្នាំ២០១៧ ការនាំចេញគិតជាទឹកប្រាក់មានចំនួន ១.១៣៤លានដុល្លារ បានកើនឡើង ៤០,៤% ធៀបនឹងខែឧសភាកន្លងទៅ ក្នុងនោះការនាំចេញទំនិញវាយនភ័ណ្ឌនិងស្បែកជើងមានចំនួន ៨៤៤លានដុល្លារ បានកើន

ឡើង ៥១,៨% ធៀបនឹងខែឧសភាកន្លងទៅ។ សរុបក្នុងឆមាសទី១ឆ្នាំ២០១៧នេះ ការនាំចូលមានចំនួន ៦.៦០១លានដុល្លារ បានកើន ៨,៣% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន និងការនាំចេញមានចំនួន ៥.១៥៥លានដុល្លារ បានកើន ៤,៧%។

៤. ក្នុងខែមិថុនា ឆ្នាំ២០១៧ រដ្ឋបាលថ្នាក់ជាតិអនុវត្តចំណូលក្នុងប្រទេសសរុបបានចំនួន ១.១៩០ប៊ីលានរៀល បានកើនឡើង ១,៤៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន គាំទ្រដោយចំណូលពន្ធលើប្រាក់ចំណេញ អាករពិសេស និងចំណូលមិនមែនសារពើពន្ធ, រីឯការអនុវត្តចំណាយនៅមានល្បឿនយឺត ពិសេសខាងផ្នែកចំណូលមូលធន។

ក្នុងឆមាសទី១ឆ្នាំ២០១៧នេះ ចំណូលក្នុងប្រទេសសរុបអនុវត្តបានចំនួន ៨.៣៩៤ប៊ីលានរៀល បានកើនឡើង ១៣,៧% បើធៀបនឹងរយៈពេលដូចគ្នានាឆ្នាំ២០១៦ (ខ្ពស់ជាងច្បាប់ថវិកា ៣,៦៤%), និងចំណាយថវិកាសរុបរដ្ឋបាលថ្នាក់ជាតិអនុវត្តបាន ៦.៩២៩ប៊ីលានរៀល (ទាបជាងច្បាប់ថវិកា ១៤,៥០%) បានកើនឡើង ២០,១% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំកន្លងទៅ។ ជារួមក្នុងឆមាសទី១នេះ តុល្យភាពថវិកាចរន្តមានអតិរេកសាច់ប្រាក់ចំនួន ៣.៣៣៤ប៊ីលានរៀល និងតុល្យភាពថវិកាសរុបមានអតិរេកសាច់ប្រាក់ ១.៤៦៥ប៊ីលានរៀល។

៥. ក្នុងខែមិថុនា ឆ្នាំ២០១៧នេះ គម្រោងវិនិយោគអនុញ្ញាតដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាមាន ២០គម្រោង អាចបង្កើតការងារបានប្រមាណ ២០ពាន់នាក់ និងគិតជាទុនវិនិយោគចំនួន ៦១៩លានដុល្លារ ក្នុងនោះគម្រោងវិនិយោគក្នុងវិស័យទេសចរណ៍ទៅលើផ្នែកមជ្ឈមណ្ឌលទេសចរណ៍និងសណ្ឋាគារមានវិនិយោគទុន ៣៦៦លានដុល្លារ។ ក្នុងឆមាសទី១ឆ្នាំ២០១៧នេះ ចំនួនគម្រោងវិនិយោគដែលបានអនុញ្ញាតមានចំនួន ៥៤គម្រោង, គិតជាទុនវិនិយោគ ១.៧៨៤លានដុល្លារ បានកើនឡើង០,១% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន ក្នុងនោះវិនិយោគវិស័យឧហ្សាហកម្មនិងទេសចរណ៍មានការថយចុះខ្លាំង ប៉ុន្តែវិនិយោគវិស័យសេវាកម្ម(មិនរាប់ចូលវិស័យទេសចរណ៍)បានកើនឡើងប្រមាណ២ដង។

៦. ក្នុងខែមិថុនា ឆ្នាំ២០១៧ ចំនួនមកដល់នៃភ្ញៀវអន្តរជាតិមានចំនួន ៣៧៨ពាន់នាក់ បានកើនឡើង ២,៥% ធៀបនឹងខែឧសភាកន្លងទៅ និងខ្ពស់ជាងខែដូចគ្នាឆ្នាំមុន ១៤,៥%។ ចំនួនមកដល់នៃភ្ញៀវអន្តរជាតិមានបម្រែបម្រួលជាលក្ខណៈរដូវកាលដោយមានកម្រិតទាបក្នុងខែឧសភាដោយសារលក្ខណៈអាកាសធាតុ ហើយនឹងមានកំណើនឡើងបន្តិចមកវិញក្នុងខែកក្កដានិងសីហា។ ក្នុងឆមាសទី១ឆ្នាំ២០១៧នេះ ចំនួនមកដល់នៃភ្ញៀវអន្តរជាតិសរុបមាន ២.៦៦៣ពាន់នាក់ បានកើនឡើង ១២,៨% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

៧. ក្នុងឆមាសទី១ឆ្នាំ២០១៧នេះ សំណើសាងសង់សរុបមាន ១.៥២៣គម្រោង បានកើនឡើង ៣៤០គម្រោង ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន, ប៉ុន្តែគិតជាផ្ទៃក្រឡាសាងសង់សរុបមាន ៧.២៨៥ពាន់ម៉ែត្រការ៉េ បានថយចុះ ៩,៥%, និងគិតជាតម្លៃសាងសង់សរុប ៤.៩៤៤លានដុល្លារ បានកើនឡើង ២៧,៤%។ ទោះមានការថយចុះគិតជាផ្ទៃក្រឡាសាងសង់សរុបក្នុងឆមាសទី១នេះក្តី ក៏សំណង់នៃផ្នែកទេសចរណ៍នៅតែមានកំណើនខ្ពស់ធៀបនឹងរយៈពេលដូចគ្នាឆ្នាំកន្លងទៅ។

៨. *ថ្លៃប្រេងឆៅ* ក្នុងខែកក្កដា ឆ្នាំ២០១៧ ថ្លៃប្រេងឆៅជារួមបានកើនឡើងបន្តពីចុងខែមិថុនាកន្លងទៅ, ក្នុងនោះប្រេងឆៅក្នុងកិច្ចសន្យាលក់១ខែខាងមុខ ប្រេងBrent ថ្លៃ ៤៨,៧ដុល្លារ/ធុង ប្រេងDubai ថ្លៃ ៤៧,៦ដុល្លារ/ធុង និងប្រេង WTI ថ្លៃ ៤៦,៧ដុល្លារ/ធុង។ យោងតាមភ្នាក់ងារអង្កេតថ្លៃប្រេងអន្តរជាតិOilSNS របស់ប្រទេសចិន កំណើនថ្លៃប្រេងឆៅក្នុងខែកក្កដានេះ គឺដោយសារមានការថយចុះនូវបរិមាណស្តុកប្រេងឆៅនិងប្រេងឥន្ធនៈរបស់សហរដ្ឋអាមេរិក, ព្រមគ្នានោះមានកំណើនទិន្នផលផលិតកម្មប្រេងឆៅរបស់សហរដ្ឋអាមេរិក កើនដល់ ៩,៤៣លានធុង/ថ្ងៃ ដែលជាទិន្នផលខ្ពស់បំផុតគិត

ចាប់ពីខែកក្កដា ឆ្នាំ២០១៥មក, រីឯផលិតកម្មប្រេងឆៅរបស់OPECបានរក្សាមានកម្រិតខ្ពស់ ក្នុងនោះមានការកើនឡើងគួរកត់សម្គាល់នូវផលិតកម្មប្រេងរបស់ប្រទេសនីហ្សេរីយ៉ានិងប្រទេសលីប៊ី។

*ថ្លៃអង្ករ* ក្នុងខែកក្កដា ឆ្នាំ២០១៧ *(១)អង្ករកម្ពុជា* អង្ករនាំចេញ(ខ្ទេច៥%)ថ្លៃ ៤២៥ដុល្លារ/តោន បានកើនឡើង ១,២% ធៀបនឹងខែមុន (ថយចុះ៤,៥% បើធៀបនឹង១ឆ្នាំមុន)។ កំណើនថ្លៃនេះ មួយផ្នែកគឺដោយសារមានការចុះកិច្ចព្រមព្រៀងទិញអង្ករជាមួយប្រទេសបង់ក្លាដេសចំនួន ១លានតោនសម្រាប់រយៈ ៥ឆ្នាំខាងមុខ ក្នុងនោះការបញ្ជាទិញសម្រាប់ឆ្នាំ២០១៧មាន ២០០ពាន់តោន, ទន្ទឹមនឹងនេះក៏មានគម្រោងចុះMoUជាមួយប្រទេសឥណ្ឌូនេស៊ីសម្រាប់ការនាំចេញអង្ករ ១លានតោនផងដែរ។ *(២)អង្ករថៃ* អង្ករនាំចេញ(ខ្ទេច៥%)ថ្លៃ ៤១៧ដុល្លារ/តោន បានថយចុះ ៩,០% ធៀបនឹងខែមុន និងថយចុះ ៥,៧% ធៀបនឹង១ឆ្នាំមុន។ យោងតាមរបាយការណ៍របស់ស្ថាប័នកសិកម្មបរទេសនៃក្រសួងកសិកម្មសហរដ្ឋអាមេរិក (USDA) ការធ្លាក់ចុះថ្លៃអង្ករថៃក្នុងខែកក្កដានេះគឺដោយសារកង្វះតម្រូវការថ្មីៗបន្ថែមទៀត។ នៅចុងខែកក្កដា ឆ្នាំ២០១៧ អាជ្ញាធរស្បៀងប្រទេសហ្វីលីពីន បានបង្វែរបន្ថយការនាំចូលអង្ករពីប្រទេសថៃជិត ២៥០ពាន់តោន ដោយនាំចូលពីប្រទេសវៀតណាមជំនួសវិញ។ *(៣)អង្ករវៀតណាម* អង្ករនាំចេញ(ខ្ទេច៥%)ថ្លៃ ៣៨៦ដុល្លារ/តោន បានកើនឡើង ៨,០% ធៀបនឹងខែមុន និងកើនឡើង ៦,៧% ធៀបនឹង១ឆ្នាំមុន។ តាមប្រភពសារព័តមានVietnamnet ប្រទេសវៀតណាមទទួលបានការបញ្ជាទិញអង្ករពីបង់ក្លាដេសចំនួន ២៥០ពាន់តោន និងបានចុះកិច្ចព្រមព្រៀងនាំចេញទៅហ្វីលីពីនចំនួន ១៧៥ពាន់, ម្យ៉ាងទៀតក៏មានការចុះកិច្ចសន្យានាំចេញទៅប្រទេសគុយបា និងម៉ាឡេស៊ីផងដែរ។ រដ្ឋាភិបាលវៀតណាមបានអនុម័តដាក់ចេញយុទ្ធសាស្ត្រថ្នាក់ជាតិដើម្បីកាត់បន្ថយបរិមាណនាំចេញនិងលើកកម្ពស់តម្លៃអង្ករ ចាប់ពីឆ្នាំ២០១៧ ដល់ ២០២០, ក្នុងនោះគោលដៅនាំចេញ ៦០% គឺទៅកាន់ទីផ្សារតំបន់អាស៊ី, ២២% ទៅកាន់ទ្វីបអាហ្វ្រិក និង ១៨% ទៅកាន់តំបន់ផ្សេងៗទៀត។

*ថ្លៃកៅស៊ូ* ក្នុងខែកក្កដា ឆ្នាំ២០១៧នេះ ថ្លៃកៅស៊ូធម្មជាតិជារួមបានកើនឡើងបន្តិចធៀបនឹងខែមិថុនាកន្លងទៅ, គិតត្រឹមខែកក្កដានេះ កៅស៊ូស្តង់ដារSTR20ថ្លៃ ១.៥១៧ដុល្លារ/តោន បានកើនឡើង ៥,៣% ធៀបនឹងខែមុន និងកៅស៊ូ SGP/MYSថ្លៃ ១.៧៤៩ដុល្លារ/តោន បានកើនឡើង ១,៧%។ យោងតាមរបាយការណ៍បឋមរបស់សមាគមប្រទេសផលិតកៅស៊ូធម្មជាតិ(ANRPC) ក្នុងខែកក្កដា ឆ្នាំ២០១៧នេះ ថ្លៃកៅស៊ូធម្មជាតិបានងើបឡើងមកវិញបន្តិចស្របតាមនិន្នាការកំណើនថ្លៃប្រេងឆៅ ជាពិសេសក្នុងរយៈពេល៣សប្តាហ៍ដំបូងនៃខែ ប៉ុន្តែបានថយចុះបន្តិចមកវិញនៅក្នុងសប្តាហ៍ទី៤ដោយសារមានកំណើនឡើងនូវសន្និធិកៅស៊ូនៅលើទីផ្សារក្នុងតំបន់ ជាពិសេសនៅប្រទេសថៃនិងម៉ាឡេស៊ី។ ក្នុងរយៈពេល៧ខែឆ្នាំ២០១៧ បរិមាណកៅស៊ូពិភពលោកផលិតបានមានចំនួន ៦,៨៤លានតោន និងបរិមាណប្រើប្រាស់មាន ៧,៤៩លានតោន នាំឱ្យមានកង្វះការផ្គត់ផ្គង់ ០,៦៥លានតោន។ ក្នុងរយៈពេល៧ខែនេះ កម្ពុជាបាននាំចេញកៅស៊ូចំនួន ៦៣ពាន់តោន បានកើនឡើង ៣០,៣% ធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំ២០១៦កន្លងទៅ។

*(ចំពោះសេចក្តីលម្អិតនៃរបាយការណ៍ សូមទាក់ទងផ្ទាល់នាយកដ្ឋានស្ថិតិ នៃអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)*

# ៣. ឧបសម្ព័ន្ធ

## សូចនាករនាំមុខ (Leading Indicators)

Construction Approval in Nationwide (0000m2)




Source: Min. LMUC

Tourist Arrivals ('000 persons)




Source: Ministry of Tourism

Total Textile Export (Mn-US$)




Source: Customs and Excise Dept.

Import of Gasoline, Steel, Cement ('000T)




Source: Customs and Excise Dept.

Rice Prices in Bangkok and Vietnam 2003 = 100




Source: MEF & Int.

Crude oil and Gasoline Price, Jan 2003 = 100




Source: MEF & Int.

# អតិផរណា រូបិយវត្ថុ និងទុនបំរុងបរទេស (Inflation, M2 and Foreign Reserve)




Source: NBC




Source: NIS




Source: NIS




Source: NIS




Source: NIS




Source: NBC

# អត្រាប្តូរប្រាក់ (Exchange Rate)

**Exchange rate R/100Đ and R/B**




Source: IMF

**Exchang Rate Mal-Ringgit/$ and Phi-Peso/$**




Source: IMF

**CPI and Exchange rate R/$**




Source: IMF

**Exchange rate EU Euro/US$ and Pound/US$**




Source: IMF

**Exchange rate Aus-$ and HK-$**




Source: IMF

**Exchange rate Sing-$ and Yen-$**




Source: IMF

# ធនាគារនិងទីផ្សារមូលបត្រ (Banking and Securities Market)

**Liquidity in Bn-R and in % to GDP**




Source: NBC

**NFA and NDA (Bn-R)**




Source: NBC

**Credit to private sector, CPS (Stock) and growth**




Source: NBC

**Credit to Private Sectors by Sector (Bn-R)**




Source: NBC

**Currency outside bank, COB and foreign deposits, FD**




Source: NBC

**CSX Index and Trade Value (Mn KHR)**




*Source: Cambodia Securities Exchange*

# ការអនុវត្តថវិកា (Budget)

### ចំណាយបៀវត្ស និង មិនមែនបៀវត្ស ឆ្នាំ ២០១៦-២០១៧




Source: MEF

### ចំណាយការពារសន្តិសុខ និង រដ្ឋបាលស៊ីវិលឆ្នាំ ២០១៦-២០១៧




### ចំណូលក្នុងប្រទេស និង ពន្ធលើពាណិជ្ជកម្ម ឆ្នាំ ២០១៦-២០១៧




### ចំណូលសារពើពន្ធ និង មិនមែនសារពើពន្ធ ឆ្នាំ២០១៦-២០១៧




### ចំណាយចរន្ត និង វិនិយោគឆ្នាំ ២០១៦-២០១៧




### ការដកសាច់ប្រាក់កម្ចីទ្វេភាគី និងពហុភាគី ឆ្នាំ ២០១៦-២០១៧



# វិនិយោគឯកជន និង ការបង្កើតការងារ (Investment and Employment)


















# វិស័យពាណិជ្ជកម្ម (Trades)

### Import and Export (mil.US$)




Source: Customs and Excise Department

### Import and Export Growth




Source: Customs and Excise Department

### Trade Balance and CA as % GDP




Source: National Bank of Cambodia, NBC, and Customs Dept.

### Export by Main Continents (mil.US$)




Souce: Customs and Excise Department, MEF
(including foreign currency exports )

### Export by Commodity Group ( in tonnes)




Souce: Customs and Excise Department, MEF

### Export Clothing and Rubber (mil.US$)




Souce: Customs and Excise Department, MEF

********

***រៀបចំដោយ***

***អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ***

***ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ***

*ព័ត៌មានផ្សេងៗ សូមទាក់ទង*

*ទូរស័ព្ទលេខ÷ ០២៣ ៤២៧៩១៣, ០៧៧ ៧០៣៤៣៦, ០៩៦ ៩៧៩១៦៨៦*

*ម៉ោងធ្វើការ÷ ៧:០០ ដល់ ១១:០០ ព្រឹក និង ២:០០ ដល់ ៥:០០ រសៀល*